ភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

# សំណងដ៏មានអត្ថន័យសម្រាប់ជនរងគ្រោះរបបខ្មែរក្រហម

រហូតមកដល់ពេលនេះ មានជំនួយជ្រោមជ្រែងយ៉ាងច្រើនសម្រាប់គម្រោងសំណងដែលដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំនៅក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែក៏នៅមានកង្វះខាតមូលនិធិនៅឡើយ ដូច្នេះនៅតែមានឱកាសផ្សេងៗដែលម្ចាស់ជំនួយសក្តានុពល អាចចូលរួមជួយសម្រេចគម្រោងទាំងនេះ ដែលនឹងផ្តល់ប្រយោជន៍ដល់ជនរងគ្រោះរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។

ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថានប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បច្ចុប្បន្ននេះកំពុងតែដឹកនាំកិច្ចខិតខំប្រឹងប្រែងថ្មីមួយដើម្បីជួសជុលព្យសនកម្មដល់ជនរងគ្រោះដែលនៅមានជីវិតពីរបបខ្មែរក្រហម។អ.វ.ត.កគឺជាតុលាការដំបូងបំផុតដែលអនុញ្ញាតឲ្យជនរងគ្រោះចូលរួមផ្ទាល់ក្នុងនាមជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី។ តាមក្របខ័ណ្ឌច្បាប់ដែលចែងអំពីកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណី អាចស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព។ បន្ថែមពីលើនេះទៀត អង្គភាពគាំពារជនរងគ្រោះមានភារកិច្ចបង្កើត និង

អនុវត្តវិធានការក្រៅប្រព័ន្ធតុលាការដើម្បីបម្រើប្រយោជន៍របស់ជនរងគ្រោះឲ្យបានកាន់តែច្រើនថែមទៀត។ នាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចកាលបរិច្ឆេទកំណត់គឺនៅត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ដែលដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែដាក់ឯកសារ និងព័ត៌មានណាបន្ថែមទៀតស្តីពីគម្រោងសំណងដែលខ្លួនស្នើសុំនៅក្នុងសំណុំរឿង ០០២/១ រួមមានបច្ចុប្បន្នភាពអំពីមូលនិធិជាដើម។ ដើមបណ្តឹងរដ្ឋប្បវេណី ស្នើតុលាការ សុំទទួលស្គាល់គម្រោងសំណងចំនួន ១៣ គម្រោងនៅក្នុងសំណុំរឿង ០០២/១ ដែលបំណងទទួលស្គាល់ជនរងគ្រោះរបបខ្មែរក្រហម ដើម្បីកាត់បន្ថយព្យសនកម្ម និង ការឈឺចាប់ដែលជនរងគ្រោះបានជួបប្រទះ។ សូមមើលតារាងដែលបានភ្ជាប់ជូនទាក់ទិននឹងព័ត៌មានអំពីសំណើគម្រោងទាំង ១៣ ដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង។

ក្នុងករណីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូង អាចផ្តល់សំណងផ្លូវចិត្ត និងសមូហភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់ខ្លួន ប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញដោយក្នុងចំណោមនោះរួមមានលក្ខខណ្ឌតម្រូវឲ្យរៀបចំឯកសារអំពីភាពគ្រប់គ្រាន់នៃមូលនិធិពីខាងក្រៅសម្រាប់គម្រោងនីមួយៗដែលបានស្នើសុំ។ ដោយសារកាលបរិច្ឆេទកំណត់ត្រឹមខែមីនាដែលខិតកាន់តែជិតហើយនោះ ទើប អង្គភាពគាំពារជងរងគ្រោះ សូមឆ្លៀតយកឱកាសនេះដើម្បីជម្រាបជូនសាធារណជន អំពីសមិទ្ធិផលដែលទទួលបានរហូតមកបច្ចុប្បន្ននេះ ហើយសូមស្នើសុំមូលនិធិស្ម័គ្រចិត្តបន្ថែមទៀតសម្រាប់ឧបត្ថម្ភដល់គម្រោងសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ។

ទោះបីជាមានជំនួយជ្រោមជ្រែងយ៉ាងច្រើនផ្នែកផ្លូវចិត្ត នយោបាយ និងហិរញ្ញវត្ថុពីសហគមន៍ម្ចាស់ជំនួយអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលកម្ពុជាយ៉ាងណាក៏ដោយ ក៏នៅតែមានឱកាសជាច្រើនទៀតដែលម្ចាស់ជំនួយសក្តានុពលអាចចូលរួមជួយសម្រេចគម្រោងសំណងដែលបានស្នើសុំ។ តាមរយៈការផ្តល់ជំនួយជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុដល់គម្រោងទាំងនេះ ម្ចាស់ជំនួយអាចជឿជាក់ប្រាកដថា ការចូលរួមចំណែករបស់ខ្លួន ត្រូវបានប្រើប្រាស់សម្រាប់គម្រោងដែលបង្កើត និង

បង្កើនជាអតិបរមានូវប្រយោជន៍ផ្ទាល់ និងយូរអង្វែងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅទូទាំងប្រទេសកម្ពុជា។

គម្រោងមួយចំនួនមិនទាន់មានមូលនិធិនៅឡើយទេ ដូច្នេះ អាចមានហានិភ័យថា តុលាការនឹងមិនទទួលស្គាល់ ឬមិនអាចអនុវត្តបាន។ ជំនួយមូលនិធិត្រូវបានស្នើដោយផ្អែកលើអាទិភាពនៃគម្រោងទាំងនេះ ដូចជា គំនិតផ្តួចផ្តើមអំពីការចងចាំសាធារណៈ គម្រោងបោះពុម្ពផ្សាយ និងចែកចាយសាលក្រមសំណុំរឿង ០០២/០១ ជូនជនរងគ្រោះ ជាសាលក្រមទាំងស្រុង និងសម្រង់សង្ខេប។ គម្រោងសំណាងមួយចំនួនបានទទួលមូលនិធិរួចហើយ ប៉ុន្តែនឹងទទួលបាន ប្រយោជន៍ពីមូលនិធិបន្ថែមទៀតដែលនឹងត្រូវប្រើប្រាស់ដើម្បីពង្រីកវិសាលបន្ថែមទៀត និងបង្កើតប្រយោជន៍គម្រោងផងដែរ។ ក្នុងចំណោមគម្រោងទាំងនេះរួមមាន គម្រោងព្យាបាលតាមរយៈការផ្តល់សក្ខី ក្រុមជួយខ្លួនដើម្បីស្តានីតិសម្បទា ការតាំងពិព័រណ៍ ចល័ត និងអចិន្ត្រៃយ៍។

សូមម្ចាស់ជំនួយសក្តានុពល ធ្វើការទំនាក់ទំនងជាមួយអង្គភាពគាំពារជនរងគ្រោះ ដើម្បីទទួលបានព័ត៌មានបន្ថែម និងការជួបពិភាក្សាដោយមានបទបង្ហាញ។

អង្គភាពគាំពារជនរងគ្រោះ គឺជាអង្គភាពផ្លូវការមួយរបស់ អ.វ.ត.ក ហើយមានភារកិច្ចសម្របសម្រួលឲ្យជនរងគ្រោះចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក លើកលែងតែតំណាងផ្លូវច្បាប់។ អង្គភាពនេះក៏មានភារកិច្ចស្វែងរកមូលនិធិ និងជំនួយជ្រោមជ្រែងពីខាងក្រៅ ហើយដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពនេះមានភារកិច្ចកំណត់ រៀបចំ និងអនុវត្តគម្រោងសំណងផ្សេងៗ។

**ទំនាក់ទំនងនៅអង្គភាពគាំពារជនរងគ្រោះ**

លោក ហង្ស វណ្ណៈ
ប្រធានអង្គភាពគាំពារជនរងគ្រោះ
សារអេឡិចត្រូនិច: hang.vannak@eccc.gov.kh
+++

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0) ២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖neth.pheaktra@eccc.gov.kh

លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

## សម្រង់សម្តីដែលត្រូវបានអនុញ្ញាតឲ្យប្រើ

ពីភាគីជាប់ពាក់ព័ន្ធ ដៃគូ និងអ្នកគាំទ្រនៅក្នុងបរិបទសេចក្តីប្រកាសព័ត៌មាននេះ។

+++

“គម្រោងសំណងទាំង ១៣ គម្រោងនេះ គឺមានសារៈសំខាន់ណាស់សម្រាប់បណ្តឹងរដ្ឋប្បវេណី មនុស្ស ជំនាន់ក្រោយ និងសង្គមកម្ពុជាទាំងមូល ពីព្រោះថាគម្រោងទាំងនេះ នឹងរំឭក ហើយបង្ហាញពី ការឈឺចាប់ដែលបានកើតឡើងពីអតីតកាល ហើយទប់ស្កាត់មិនឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត នៅក្នុងប្រទេសកម្ពុជា”។

លោក នួន សុវណ្ណ

ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០១ នៅ អ.វ.ត.ក

+++

“ក្រោយពីទទួលបានព័ត៌មានបច្ចុប្បន្នភាពនៅក្នុងការជួបជុំគ្នាថ្នាក់តំបន់នាពេលថ្មីៗនេះរបស់ដើម បណ្តឹងរដ្ឋប្បវេណី ដែលបានរៀបចំដោយអង្គភាពគាំពារជនរងគ្រោះនៅខេត្តស្វាយរៀង ខ្ញុំពេញចិត្តនឹង សំណងផ្លូវចិត្ត និងសម្ហូហភាព និងវិធានការក្រៅតុលាការនៅ អ.វ.ត.ក ជាពិសេសគម្រោងកសាង កន្លែងគោរពវិញ្ញាណក្ខន្ធមួយនៅសារមន្ទីរទួលស្លែង និងការតាំងពិព័រណ៍នៅសារមន្ទីរខេត្តផ្សេងៗ”។

លោកស្រី កែវ អ៊ុក

ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០១ នៅ អ.វ.ត.ក

+++

*“អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់ជូនជនរងគ្រោះកម្ពុជានូវឱកាសពិសេសមួយដើម្បីទទួលបានការធូរស្រាលខ្លះ ពីការឈឺចាប់របស់ខ្លួនតាមរយៈគម្រោងអាទិភាពដែលបានអនុម័តសម្រាប់អនុវត្តតាមលទ្ធផលសាលក្រមនៅក្នុងដំណាក់កាលទី ១ នៃសំណុំរឿង០០២។ ចាំបាច់ដែលរដ្ឋាភិបាលផ្សេងៗ និងប្រភពសប្បុរសធម៌ផ្សេងៗ ត្រូវផ្ដល់ជំនួយហិរញ្ញវត្ថុដែលត្រូវការយ៉ាងខ្លាំង សម្រាប់គម្រោងទាំងនេះ នៅត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ជាកាលបរិច្ឆេទកំណត់ដែលតុលាការបានកំណត់”។*

ឯកអគ្គរដ្ឋទូត David Scheffer

អ្នកជំនាញពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកជំនួយអង្គការសហប្រជាជាតិសម្រាប់សាលាក្ដីខ្មែរក្រហម

+++

*“សំណងសំខាន់ណាស់សម្រាប់ជនរងគ្រោះទាំងអស់។ ជនរងគ្រោះរបបខ្មែរក្រហម ជារឿយៗតែងតែបង្ហាញពីតម្រូវការចង់បានសំណង ពីព្រោះថា សំណងអាចសងការខូចខាត និងព្យាបាលការឈឺចាប់របស់គាត់បានមួយកម្រិត។ សំណងគឺជានិមិត្តសញ្ញានៃការទទួលខុសត្រូវដែលជនរងគ្រោះ ចង់ឃើញអ្នកប្រព្រឹត្ត ឬជនឧក្រិដ្ឋ មានការទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានធ្វើ។ នៅក្នុងបរិបទ អ.វ.ត.ក សំណងដែលជានិមិត្តសញ្ញា ខាងផ្លូវចិត្ត និងសមូហភាព គឺមានសារៈសំខាន់ណាស់ ហើយចាំបាច់សម្រាប់ជនរងគ្រោះដែលនៅមានជីវិតពីរបបខ្មែរក្រហម ពីព្រោះថាសំណងអាចជួយលើកស្ទួយតម្លៃ និងសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ។ សំណង ក៏អាចទទួលស្គាល់ការឈឺចាប់ និងការបាត់បង់ដែលជនរងគ្រោះបានជួបប្រទះ។ អង្គការយុវសន្តិភាព យល់ពីភាពសំខាន់នៃសំណង ហើយយើងកំពុងធ្វើការជាមួយអង្គភាពគាំពារជនរងគ្រោះ/អ.វ.ត.ក ដើម្បីឆ្លើយតបតាមតម្រូវការរបស់ជនរងគ្រោះ ហើយយើងសង្ឃឹមថា កម្មវិធីសំណងរបស់ អ.វ.ត.ក អាចជួយព្យាបាលជនរងគ្រោះដែលនៅមានជីវិត និងនាំឲ្យមានការផ្សះផ្សាសង្គមសម្រាប់ប្រជាជនកម្ពុជាទាំងអស់។ យើងត្រូវការជំនួយជ្រោមជ្រែងពីម្ចាស់ជំនួយ ដើម្បីអនុវត្តគម្រោងសំណង និងគម្រោងវិធានការក្រៅតុលាការផ្សេងទៀត ដើម្បីផ្ដល់ប្រយោជន៍ដល់ជនរងគ្រោះ និងចូលរួមទប់ស្កាត់មិនឲ្យមានអំពើឃោរឃៅ និងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរម្ដងទៀតនៅក្នុងប្រទេសកម្ពុជា នាពេលអនាគត”។*

លោក ឡុង ខែត្រ

នាយក អង្គការយុវសន្តិសន្តិភាព

+++

“ដោយសហការជាមួយផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងផ្នែកគាំពារជនរងគ្រោះ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំតម្កើង និងគ្រប់គ្រងការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ការតាំងពិព័រណ៍ទាំងនេះ គឺជាការវិវត្តមួយដ៏សំខាន់មិនមែនគ្រាន់តែដើម្បីការព្យាយាមរបស់កម្ពុជា ក្នុងការស្វែងរកការផ្សះផ្សា និងយុត្តិធម៌បច្ចុប្បនេះប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីអប់រំយុវជនកម្ពុជាជំនាន់ក្រោយផងដែរ។ បន្ថែមពីលើនេះទៀត ដោយសហការជាមួយផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងផ្នែកគាំពារជនរងគ្រោះ មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងតែបញ្ចប់ការសរសេរសៀវភៅមួយជំពូកស្តីពីប្រវត្តិនៃការជម្លៀសប្រជាជនកម្ពុជាដោយបង្ខំ និងព្រឹត្តិការណ៍ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ។ ជំពូកមេរៀននេះ ដែលនឹង បញ្ចូលទៅក្នុងសៀវភៅមគ្គុទេសន៍សម្រាប់គ្រូ៖ ការបង្រៀនប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩) សរសេរដោយបណ្ឌិត ជា ផល្លា និង *Christopher Dearing* នឹងរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលនៅមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ និងជាមេរៀនប្រវត្តិសាស្ត្រដែលគ្រូបង្រៀន អាចប្រើប្រាស់នៅក្នុងថ្នាក់រៀននៅក្នុងប្រទេសកម្ពុជា។ ចុងក្រោយ គម្រោងទាំងពីរនេះ នឹងអប់រំសាធារណជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងជាឧបករណ៍ធានាថា ប្រវត្តិសាស្ត្រនេះនឹងមិនត្រូវបានបំភ្លេចចោលឡើយ។

គម្រោងទាំងនេះនឹងមិនអាចដំណើរការទៅបានទេ ប្រសិនបើគ្មានការជួយជ្រោមជ្រែងដ៏សប្បុរសពីរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាល្លឺម៉ង់។ មូលនិធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់គម្រោងទាំងនេះ ទទួលបានតាមរយៈអង្គភាពគាំពារជនរងគ្រោះ/អ.វ.ត.ក ដែលទទួលបានជំនួយគាំទ្រពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់។ មជ្ឈមណ្ឌលឯកសារ

កម្ពុជា ក៏សូមអរគុណដល់គម្រោងសេវាសន្តិភាពជនស៊ីវិលរបស់កម្មវិធីអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ) ចំពោះមូលនិធិដ៏សប្បុរសសម្រាប់ការបោះពុម្ពជំពូកមេរៀននេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏នឹងធ្វើការសហការជាមួយនឹងរដ្ឋាភិបាលកម្ពុជា។ ចំពោះគម្រោងតាំងពិព័រណ៍នៅតាមសារមន្ទីរ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសារមន្ទីរជាតិ ដើម្បីបង្កើត និងចាត់ចែងការតាំងពិព័រណ៍ចំនួន៥ នៅតាមសារមន្ទីរ។ ដោយសហការជាមួយស្ថាប័នទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងចងក្រងឯកសាររឿងរបស់ជនរងគ្រោះដែលនៅមានជីវិតពីរបបខ្មែរក្រហម និងប្រវត្តិរបស់ភូមិ ទីកន្លែងសាកសព និងគុកនៅទូទាំងប្រទេសកម្ពុជា ដែលអំពើឃោរឃៅបានកើតឡើង។ ចំពោះគម្រោងជំពូកមេរៀន មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដែលបានអនុញ្ញាតឲ្យប្រើប្រាស់កម្មវិធីអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីអំពើប្រល័យពូជសាសន៍នៅគ្រប់សាលាទាំងអស់នៅទូទាំងប្រទេសកម្ពុជា។

លោក ឆាង យុ
នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា



EN ERN: 00975579-00975585

## សង្ខេបអំពីសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០១

[សម្គាល់៖ មូលនិធិត្រូវបានស្វែងរកតាមអាទិភាពគម្រោង ដាក់ពណ៌លឿង)

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **១. ទិវាជាតិនៃការចង់ចាំ** | រាជរដ្ឋាភិបាលកម្ពុជា | គម្រោងនេះមានបំណងបង្កើតទិវាជាតិនៃការចងចាំជាផ្លូវការដើម្បីរំឭកដល់ជនរងគ្រោះ និងអ្នកនៅមានជីវិតពីរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញរួចហើយនូវការយល់ព្រមជាគោលការណ៍ដើម្បីបង្កើតទិវានេះ។ | មិនអាចអនុវត្តបាន | មិនតម្រូវឲ្យមានមូលនិធិ |
| **២. គំនិតផ្តើមផ្តើមបង្កើតកន្លែងរំឭកវិញ្ញាណក្ខន្ធសាធារណៈ** | អង្គការក្តីករុណា (KdK) និងអង្គការ យុវសន្តិភាព (YfP) | គម្រោងនេះមានបំណងបង្កើតកន្លែងរំឭកវិញ្ញាណក្ខន្ធមួយចំនួនតូច ដោយមានសកម្មភាពអប់រំ និងនិយាយរឿងពិតដែលជាប់ពាក់ព័ន្ធ តាមរយៈដំណើរការប្រឹក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី សហគមន៍មូលដ្ឋាន និងភាគីជាប់ពាក់ព័ន្ធផ្សេងទៀត នៅកន្លែងរំឭកវិញ្ញាណក្ខន្ធទូទាំងប្រទេសកម្ពុជា។ | [រង់ចាំម្ចាស់ជំនួយ] | មិនទាន់មានមូលនិធិនៅឡើយ ** |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **៣. កន្លែងគោរពវិញ្ញាណក្ខន្ធ សម្រាប់ជនរងគ្រោះខ្មែរក្រហម៖ សម្រាប់អ្នកដែលលែងនៅទីនេះហើយ"** | អ៊ឹង សេរ៉ា (សិល្បករ) សមាគម ANVAYA ស្ថានទូតបារាំង | គម្រោងនេះមានបំណងបង្កើត និងកសាងបូជនីយស្ថានមួយចំនួននៅលើកន្លែងវាងត្រីកោណនៅជាប់ស្ថានទូតបារាំងប្រចាំនៅភ្នំពេញ។ បូជនីយស្ថានទាំងនេះនឹងរំឭកពីព្រឹត្តិការណ៍ដែលបានប៉ះពាល់ដល់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ កាលពីខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលអ្នករស់នៅទីក្រុងនេះ ត្រូវបានខ្មែរក្រហមបង្ខំ ឲ្យចាកចេញចោលពីផ្ទះរបស់ពួកគាត់។ | សាធារណរដ្ឋបារាំង /សមាគមន ANVAYA/OUBA SAS/ACYC SARL Architectes | មានមូលនិធិ |
| **៤. បូជនីយដ្ឋានសម្រាប់ជនរងគ្រោះខ្មែរក្រហមនៅប្រទេសបារាំង** | សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) | គម្រោងនេះមានបំណងកសាងបូជនីយស្ថានមួយសម្រាប់ជនរងគ្រោះរបបខ្មែរក្រហមដែលរស់នៅប្រទេសបារាំង នៅវត្ត Great Pagoda of Vincennes នៅក្នុងទីក្រុងប៉ារីស ដើម្បីធ្វើជាកន្លែងដែលអ្នកនៅមានជីវិត និងបងប្អូនជនរងគ្រោះ អាចធ្វើពិធីបុណ្យផ្សេងៗ និងរំឭកវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់។ | [រង់ចាំម្ចាស់ជំនួយ] | មិនទាន់មានមូលនិធិ |

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| ៥. ការព្យាបាលតាមសក្ខី | អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) | គម្រោងនេះ ផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ២00នាក់ នូវឱកាសចូលរួមការព្យាបាលតាមរយៈ ការផ្តល់សក្ខីកម្ម ក្នុងនោះពួកគាត់ត្រូវបានអញ្ជើញឲ្យនិយាយអំពីបទពិសោធន៍ឈឺចាប់របស់គាត់ ដោយមានការជួយជ្រោមជ្រែង និងជំនួយពីអ្នកជំនាញសុខភាពផ្លូវចិត្ត ដែលជួយពួកគាត់រៀបចំសក្ខីកម្មរបស់គាត់ ជាទម្រង់លាយលក្ខណ៍អក្សរ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកផ្តល់ជំនួយ អានសាច់រឿងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពិធីបុណ្យសាធារណៈ តាមជំនឿសាសនានិងវប្បធម៌របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ។ | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ)/ StiftungKriegstrauma-Therapie | មានមូលនិធិ/ ស្វះស្វែងរកមូលនិធិបន្ថែមទៀត * |
| ៦.ក្រុមជួយខ្លួនឯងដើម្បីស្តារនីតិសម្បទា | អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) | គម្រោងនេះនឹងបង្កើតក្រុមជួយខ្លួនឯងនៅតាមមូលដ្ឋាន និងមានការសម្របសម្រួលប្រកបដោយវិជ្ជាជីវៈ។ ក្រុមជួយខ្លួនឯង គឺជាសមាគមស្ម័គ្រចិត្ត ដែលជួបជុំគ្នា ដើម្បីជួយខ្លួនឯង និងជួយគ្នាទៅវិញទៅមក បង្កើនការយល់ដឹង អភិវឌ្ឍជំនាញដោះស្រាយបញ្ហា និងជម្នះលើការឈឺចាប់ពីអតីតកាល។ | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ)/StiftungKriegstrauma-Therapie | មានមូលនិធិ/ ស្វះស្វែងរកមូលនិធិបន្ថែមទៀត * |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **៧. ការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃ** | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) | ការតាំងបង្ហាញជាអចិន្ត្រៃយ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ នឹងមានដាក់តាំងនៅសារមន្ទីរខេត្តចំនួន ៥ គឺខេត្ត បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ តាកែវ និងស្វាយរៀង។ ការតាំងបង្ហាញនេះដំបូងនឹងផ្តោតលើការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃ ប៉ុន្តែប្រធានបទអាចផ្លាស់ប្តូរតាមពេលវេលា ដើម្បីឆ្លុះបញ្ចាំងពីផ្នែកផ្សេងទៀតនៃបទពិសោធន៍របស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ) | មានមូលនិធិ/ ស្វះស្វែងរកមូលនិធិបន្ថែមទៀត * |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **៨. ការតាំងពិព័រណ៍ចល័តស្ដីពីការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃ** | អង្គការក្ដីករុណា (KdK) និងអង្គការ យុវសន្តិភាព (YfP) | គម្រោងនេះគឺជាការតាំងពិព័រណ៍អន្តរសកម្មភាព ដែលអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម អំពី អ.វ.ត.ក និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសការជម្លៀសប្រជាជនដោយបង្ខំ តាមរយៈការតាំងបង្ហាញប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយចម្រុះ រួមមានខ្សែភាពយន្ត និងសម្ភារៈរូបភាពសម្លេងផ្សេងទៀត ជាមួយនឹងសកម្មភាពចូលរួម ដែលលើកទឹកចិត្តអ្នកទស្សនា ឱ្យបង្កើនចំណេះដឹង និងឆ្លុះបញ្ចាំងស៊ីជម្រៅលើបញ្ហាដែលបានបង្ហាញ ទាក់ទងនឹងជីវិតផ្ទាល់ខ្លួន និងសង្គមកម្ពុជាបច្ចុប្បន្ន។ | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ) | មានមូលនិធិ/ ស្វះស្វែងរកមូលនិធិបន្ថែមទៀត * |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **៩. ជំពូកមេរៀនស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃ សម្រាប់សៀវភៅមគ្គុទេសន៍សម្រាប់គ្រូបង្រៀន** | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) | ជំពូកបន្ថែមមួយស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងកន្លែងសម្លាប់ទួលពោធិ៍ជ្រៃ នឹងត្រូវបញ្ចូលទៅក្នុងសៀវភៅមគ្គុទេសន៍សម្រាប់គ្រូបង្រៀន៖ ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ (ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩) ដែលត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីអប់រំស្តីពីអំពើប្រល័យពូជសាសន៍ទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។ ជំពូកមេរៀននេះ នឹងមានលក្ខណៈ អន្តរសកម្មភាព និងផ្តោតលើវិធីសាស្ត្រសិក្សាសិស្សជាមជ្ឈមណ្ឌល ក្នុងគោលបំណងដើម្បីបង្កើតការគិតឱ្យបានគ្រប់ជ្រុងជ្រោយ សកម្មភាពរៀនដោយឯករាជ្យ ឆ្លុះបញ្ចាំង និងពាក់ព័ន្ធជាមួយនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងបទពិសោធ៍របស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ | សេវាសន្តិភាពស៊ីវិល (GIZ)/ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ) | មានមូលនិធិ |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| ១០. មណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍នៅសំរោងក្នុង | អង្គការយុវសន្តិភាព (YfP) | មជ្ឈមណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍ នឹងត្រូវកសាង និងថែទាំនៅភូមិសំរោងក្នុង ខេត្តបាត់ដំបង ដែលជាទីកន្លែងប្រវត្តិសាស្ត្រមួយនៃការសម្លាប់រង្គាលនៅរបបខ្មែរក្រហម។មជ្ឈមណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍ នឹងមានមណ្ឌលព័ត៌មានមួយកន្លែង សារមន្ទីរមួយកន្លែង និងបន្ទប់ពិភាក្សាមួយកន្លែង។ សហគមន៍នឹងចូលរួមចំណែកជាធនធានមនុស្ស និងហិរញ្ញវត្ថុដើម្បីកសាង និងថែរក្សាមជ្ឈមណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍ ដែលមានបំណងកែប្រែអតីតកាលអវិជ្ជមានរបស់តំបន់នេះទៅជាអនាគតដ៏មានភាពវិជ្ជមានវិញ តាមរយៈការជំរុញឲ្យសហគមន៍មូលដ្ឋាន និងដើមបណ្តឹងរដ្ឋប្បវេណី កែប្រែតំបន់នេះទៅជាកន្លែងរំឭកវិញ្ញាក្ខន្ធ កន្លែងចងចាំ ពិភាក្សាគ្នា និងអប់រំ។ | ទីភ្នាក់ងារស្វីសដើម្បីអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) | មានមូលនិធិ |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **១១. សៀវភៅរឿងដើមបណ្ដឹងរដ្ឋប្បវេណី ដោយមានបង្ហាញរូបភាព** | គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) | គម្រោងនេះនឹងបោះពុម្ពផ្សាយលើកទីពីរនូវសៀវភៅរឿងដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ។ គម្រោងបោះពុម្ពសៀវនេះ ធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ក្លាយជាអ្នកនិទានរឿង ដោយនិយាយរឿងរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ និងជារូបភាពបង្ហាញ។ សៀវភៅនេះនឹងអនុញ្ញាតឲ្យអ្នកដែលជាធម្មតាត្រូវបានចាត់ទុកថាមានសំឡេងគ្មានអំណាច និងឆ្ងាយដាច់ពីគេ មានសំឡេងឡើងវិញ និងមានអារម្មណ៍ថាបានទទួលយុត្តិធម៌តាមរយៈការទទួលស្គាល់។ | សេវាសន្តិភាពស៊ីវិល (GIZ)/ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ) | មានមូលនិធិ |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **១២. ការបោះពុម្ព និង ចែកចាយសាលក្រមសំណុំរឿង ០០២/០១** | អង្គភាពសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ អ.វ.ត.ក | គម្រោងនេះស្វះស្វែងផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីនូវសាលក្រមសំណុំរឿង ០០២/០១ ជាសាលក្រមទាំងស្រុង និងជាសម្រង់សង្ខេប។ សាលក្រមសង្ខេបគឺជាអត្ថបទសង្ខេបជាផ្លូវការរបស់ អ.វ.ត.ក និង/ឬជាអត្ថបទសង្ខេបរៀបចំជាពិសេសដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី ក្រុមគ្រួសាររបស់ពួកគាត់ និងសាធារណជនទូទៅ ងាយទទួលបាន និងចាប់អារម្មណ៍។ សាលក្រមសង្ខេបនឹងពន្យល់ពីសាលក្រម និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយពន្យល់ជាពាក្យសាមញ្ញ។ អត្ថបទនេះ នឹងអមដោយរូបភាពផ្តល់ព័ត៌មាន និងកំសាន្ត ដែលនឹងជួយពន្យល់ពីចំណុចសំខាន់ៗរបស់អត្ថបទ។ | [រង់ចាំម្ចាស់ជំនួយ] | **មិនទាន់មានមូលនិធិ** |



EN ERN: 00975579-00975585

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** | ស្ថានភាពមូលនិធិ |
|---|---|---|---|---|
| **១៣. ការផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅលើគេហទំព័ររបស់ អ.វ.ត.ក** | អ.វ.ត.ក | ឈ្មោះ និងព័ត៌មានអត្តសញ្ញាណទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវចុះផ្សាយនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ និងនៅលើគេហទំព័ររបស់ អ.វ.ត.ក ដើម្បីជាមធ្យោបាយមួយទទួលស្គាល់ការឈឺចាប់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានជួបប្រទះ ហើយទទួលស្គាល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី។ | មិនអាចអនុវត្តបាន | មិនតម្រូវឲ្យមានមូលនិធិ |

***សម្គាល់៖***

** គម្រោងទាំងនេះ ត្រូវបានផ្តល់មូលនិធិក្នុងកម្រិតមូលដ្ឋាន ហើយកំពុងស្វះស្វែងរកមូលនិធិបន្ថែមទៀតដើម្បីពង្រីកវិសាលភាពរបស់គម្រោងឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីថែមទៀត។*

*** គម្រោងនេះមានថវិកាសម្រាប់កសាងកន្លែងគោរពវិញ្ញាណក្ខន្ធ ចំនួនប្រហែល ៦ កន្លែង ទោះបីយ៉ាងណា តម្លៃអនុវត្តគម្រោងអាចកាត់បន្ថយសល់ចំនួនកន្លែងគោរពវិញ្ញាណក្ខន្ធតិចជាងនេះប្រសិនបើចាំបាច់។*

****មូលនិធិសរុបស្មើ **៦០២. ៧២៧, ៤២** ដុល្លារ ត្រូវបានរៃអង្គាសសម្រាប់គម្រោងទាំងនេះ រួមមានមូលនិធិចំនួន **៥២១.០០១,៦០** ដែលអង្គភាពគាំពារជនរងគ្រោះរៃអង្គាសបាន។*

Phnom Penh 25 February 2014

## PRESS RELEASE

## MEANINGFUL REPARATIONS FOR VICTIMS OF KHMER ROUGE REGIME

**Wide ranging support has been secured for the Civil Parties' requested reparation projects in Case 002/01, but there remains a funding gap and, consequently, various opportunities still exist for potential donors to engage in the realization of these projects, which will benefit the victims of the Democratic Kampuchea regime from 1975-1979.**

The Victims Support Section (VSS) and the Civil Party Lead Co-Lawyers of the Extraordinary Chambers in the Courts of Cambodia (ECCC) – in close cooperation with governmental and non-governmental organizations – are currently leading a groundbreaking effort to bring redress to the survivors of the Khmer Rouge regime. The ECCC is the first court of its kind allowing victims to participate directly in the proceedings as parties. In accordance with the legal framework governing the ECCC proceedings, the Civil Parties can seek collective and moral reparations. In addition, the VSS is mandated to develop and implement non-judicial measures to serve the broader interests of victims.

The Trial Chamber has recently set the deadline of 31 March 2014 by which Civil Parties must submit any further documentation and information on the reparation projects they seek in Case 002/01, including updates on funding. Civil Parties seek the Court's recognition of thirteen reparation projects in Case 002/01 which aim to provide acknowledgement to the victims of the Khmer Rouge regime in order to mitigate the harms and suffering they have experienced. Please see the attached table, for information about the thirteen proposed projects submitted to the Trial Chamber.

In case of conviction of the accused, the Trial Chamber may grant moral and collective reparations to the Civil Parties in its judgment if certain conditions are fulfilled; among them the requirement for documentation of sufficient external funding for each proposed

project. With the March deadline drawing near, the VSS takes this opportunity to inform the public about the achievements to date and to seek additional voluntary funding for the reparation projects sought by the Civil Parties.

Despite wide ranging moral, political and financial support from the international donor community, the Royal Government of Cambodia and Cambodian civil society organizations, there are still various opportunities for potential donors to engage in the realization of the requested reparation projects. By providing financial support to these projects, donors can be secure in the knowledge that their contributions are used for programming that creates and maximizes direct and lasting benefits for Civil Parties and victims throughout Cambodia.

A number of projects do not yet have secured funding and, consequently, are at risk of not being recognized by the Court, nor implemented. Funding is sought on a priority basis for these projects, namely the Public Memorials Initiative and the project to publish and distribute the Case 002/01 judgment to civil parties in full and illustrated summary form. Several proposed reparation projects have already secured funding, but would benefit from additional funds which would be used to further expand the reach and enhance the benefit of the projects. Among these are the Testimonial Therapy, Self-Help Groups for Rehabilitation, Mobile Exhibition and Permanent projects.

Potential donors are encouraged to contact the VSS for further information and a presentation meeting.

The VSS is an official organ of the ECCC and is mandated to facilitate and coordinate victims' participation in the ECCC's proceedings, except legal representation. Furthermore, the Section is mandated to seek external funding and support and, in close cooperation with the Civil Party Lead Co-Lawyers, to identify, design and later implement reparation projects.

**VSS Contact**


Mr. Hang Vannak
Chief of VSS
Email: hang.vannak@eccc.gov.kh


+++

**Media Contact Information**


Mr. Neth Pheaktra
Press Officer
Mobile phone: +855 (0)12 488 156
Land line: +855 (0)23 861 564
Email: neth.pheaktra@eccc.gov.kh

Mr. Lars Olsen
Legal Officer
Mobile: +855 (0)12 488 023
Land line: +855 (0)23 861 669
Email: olsenl@un.org

**Authorized Quotations**
from stakeholders, partners and supporters in context with this press statement:

+++
"The thirteen reparation projects are very important to Civil Parties, youger generations, and the Cambodian society as a whole as they will remind and show sufferrings happend in the past, and prevent the non-occurence of the Khmer Rouge regime in Cambodia."

Mr. Nuon Sovan,
Civil Party in Case 002/01 at the ECCC
+++

*"Having received updates during the recent Regional Civil Party Meeting, organized by the VSS in Svay Rieng province, I am satisfied with the collective and moral reparations as well as non-judicial measures of the ECCC; especially the projects on building a memorial at Tuol Sleng Museum and exhibitions in provincial museums."*

Ms. KEO Ouk,
Civil Party in Case 002/01 at the ECCC

+++
*"The Trial Chamber has afforded the Cambodian victims with a unique opportunity to realize some small measure of relief from their suffering through the prioritized projects approved for implementation depending on the outcome of the verdict in Phase 01 of Case 002. It is imperative for governments and philanthropic sources to lend their much-needed financial support to these projects by 31 March 2014, which is the deadline set by the Court."*

Ambassador David Scheffer,
U.N. Secretary-General's Special Expert on United Nations Assistance to the Khmer Rouge Trials

+++
*"Reparations are very important for all victims. Victims of the Khmer Rouge regime often express their need for reparations because reparations can repair the damage and heal the sufferings to a certain extent. Reparations are a symbol of accountability that victims want to see that perpetrators or criminals have responsibility for what they did. In the context of ECCC, symbolic, moral, and collective reparations are very crucial and needed for the Khmer Rouge victim-survivors because they can help to restore the value and dignity of the victims. Reparations can also acknowledge the sufferings and the loss experienced by victims. Youth for Peace understands the importance of reparations and we are working alongside the VSS/ECCC to meet of the needs of the victims and we hope that the ECCC Reparation Program can bring healing for victim-survivors and social reconciliation for all Cambodian people. We need the support from donors to implement the reparation projects and other non-judicial measure projects in order to*

*give benefit to the victims and to contribute to non-recurrence of atrocities and gross human rights violations in Cambodia in the future."*

Mr. LONG Khet,
Director, Youth for Peace

+++

*"In collaboration with the Civil Party Lead Co-Lawyers Section (LCLS) and the Victims Support Section (VSS) of the Extraordinary Chambers in the Courts of Cambodia (ECCC), the Documentation Center of Cambodia (DC-Cam) will design, install and manage permanent exhibitions on the history of Democratic Kampuchea (DK). These exhibitions are an important development not only for Cambodia?s struggle for reconciliation and justice today, but the education of its youth for generations to come. In addition, in collaboration with the LCLS and VSS, DC-Cam is completing the development of a book chapter on the history of the forced transfer of Cambodians and the events that occurred at Tuol Po Chrey. The book chapter, which will be included in the Teacher's Guidebook: The Teaching of a History of Democratic Kampuchea (1975-1979), by Dr. PhalaCheaand Christopher Dearing, will provide personal accounts of survivors of the Democratic Kampuchea period as well as history lessons that teachers can use in Cambodian classrooms. Ultimately both projects will not only educate the public on DK history, but also serve as instruments for ensuring this history is never forgotten.*

*These projects would not be possible without the generous support of the Cambodian and German governments. DC-Cam?s funding for these projects comes by way of the Victims Support Section/ECCC, which receives its support from the German Federal Ministry for Economic Cooperation and Development (BMZ). In addition, DC-Cam wishes to give thanks to the Civil Peace Service of Deutsche GesellschaftfürInternationaleZusammenarbeit (GIZ) GmbH for its generous funding for the publication of the book chapter.*

*DC-Cam will also be working with the Cambodian government. On the museum exhibitions project, DC-Cam will work with the Ministry of Culture and Fine Arts and the Cambodian National Museum to create and manage five museum exhibitions. Together with these institutions, DC-Cam will document the stories of survivors and the histories of villages, burial sites, and prison centers across the country where mass atrocities took place. On the book chapter project, DC-Cam will be collaborating with the Ministry of Education, Youth and Sport (MOEYS), which has mandated the use of DC-Cam's genocide education curriculum in all schools throughout Cambodia."*

Mr. Youk Chhang,
Director of the Documentation Center of Cambodia (DC-Cam)
+++

## Overview of Civil Party Reparation Requests in Case 002/01

[**NB**: Funding is sought on a priority basis for the projects highlighted in yellow]

| Name | Main Project Partners (implementation) | Description | Current Donors*** | Funding Status |
|---|---|---|---|---|
| **1. National Day of Remembrance** | Royal Government of Cambodia (RGC) | Project to create and official national day of remembrance honoring victims and survivors of the Khmer Rouge in Cambodia. Royal Government of Cambodia (RGC) has already expressed its principled agreement to create such a day. | Not Applicable | No funds required |
| **2. Public Memorials Initiative** | Kdei Karuna (KdK) & Youth for Peace (YfP) | Project to develop a small number (~6) of public memorial sites with related truth-telling and educational activities through a consultative process with civil parties, local communities and other stakeholders at sites distributed throughout Cambodia. | [*pending donor*] | Funds not yet secured** |
| **3. Memorial for Khmer Rouge Victims: "For Those Who Are No Longer Here"** | Séra ING (artist) ANVAYA Association Embassy of France | Project to produce and stage a group of sculptural monuments on a raised triangular platform adjacent to the Embassy of France in Phnom Penh. The monuments will evoke events which affected the population of Phnom Penh in April 1975 when the city's inhabitants were forced by the Khmer Rouge to abandon their homes. | Republic of France/Association ANVAYA/OUBA SAS/ACYC SARL Architectes | Funds secured |
| **4. Monument for Khmer Rouge Victims in France** | International Federation for Human Rights (FIDH) | The construction of a monument for victims of the Khmer Rouge living in France at the Great Pagoda of Vincennes in Paris in order to provide a space where survivors and relatives of the victims can hold ceremonies and honor the memory of those lost. | [*pending donor*] | Funds not yet secured |

| Name | Main Project Partners (implementation) | Description | Current Donors*** | Funding Status |
|---|---|---|---|---|
| **5. Testimonial Therapy** | Transcultural Psychosocial Organization (TPO) | Project provides approximately 200 civil parties the opportunity to participate in testimonial therapy, during which they are invited to talk about their traumatic experiences with the support and assistance of a mental health professionals who helps them to prepare their testimony in the form of a written document. The civil party or their support person later reads portions of their story in a public ceremony held in accordance with the civil party's religious/spiritual beliefs and cultural practices. | Federal Ministry for Economic Cooperation and Development (BMZ)/ StiftungKriegstrauma-Therapie | Funds secured/ Additional funds sought* |
| **6. Self-Help Groups for Rehabilitation** | Transcultural Psychosocial Organization (TPO) | Project will create locally-based and professionally facilitated self-help groups, which are voluntary associations of people that meet to help themselves and each other increase their level of well-being, develop coping skills and overcome traumatic suffering. | Federal Ministry for Economic Cooperation and Development (BMZ)/StiftungKriegstrauma-Therapie | Funds secured/ Additional funds sought* |
| **7. Permanent Exhibition on Forced Transfer & Tuol Po Chrey** | Documentation Center of Cambodia (DC-Cam) | Permanent exhibitions on forced transfer and the executions at Tuol Po Chrey will be established in five Cambodian provincial museums at Battambang, Banteay Meanchey, Kampong Thom, Takeo, and Svay Rieng provinces. While the exhibition will initially be focused on forced transfer and Tuol Po Chrey, the specific topics may change over time to reflect other aspects of victims' and civil parties' experiences. | Federal Ministry for Economic Cooperation and Development (BMZ) | Funds secured Additional funds sought* |
| **8. Mobile Exhibition on Forced Transfer & Tuol Po Chrey** | Kdei Karuna & Youth for Peace (YfP) | The project is an interactive exhibition that educates Cambodians about Khmer Rouge History, the ECCC and personal experiences of civil parties, especially forced transfers, through a multimedia exhibition combining film and other audiovisual material with participatory activities that encourage visitors to expand their knowledge and deeply reflect on the issues presented, relating them to their personal lives and contemporary Cambodian society. | Federal Ministry for Economic Cooperation and Development (BMZ) | Funds secured/ Additional funds sought* |

| Name | Main Project Partners (implementation) | Description | Current Donors*** | Funding Status |
|---|---|---|---|---|
| **9. New Chapter on Forced Transfer & Tuol Po Chrey in Teacher's Guidebook** | Documentation Center of Cambodia (DC-Cam) | An additional chapter on forced transfer and the Tuol Po Chrey execution site will be included in the *Teacher's Guidebook: The Teaching of A History of Democratic Kampuchea (1975-1979)* which is used in all DC-Cam's genocide education programs, in collaboration with the Cambodian Ministry of Education, Youth and Sport. The chapter will be interactive and focused on student-centered learning methodologies for the purpose of cultivating critical thinking, independent learning activities, reflection, and engagement on the history of Democratic Kampuchea and the experiences of victims and civil parties. | Civil Peace Service (GIZ)/Federal Ministry for Economic Cooperation and Development (BMZ) | Funds secured |
| **10. Community Peace Learning Center in Samrong Khnong** | Youth for Peace (YfP) | A Community Peace Learning Center (CPLC) will be constructed and maintained in Samrong Khnong village, Battambang province—a historical sight where mass killings of the Khmer Rouge Regime occurred. The CPLC will consist of an information center, a museum and a dialogue room. The community will contribute human and financial resources to the development and maintenance of the CPLC which aims to transform the site's negative past into a positive future by engaging the local community and civil parties in transforming the site into a place of commemoration, remembrance, dialogue and education. | Swiss Agency for Development and Cooperation (SDC) | Funds secured |
| **11. Illustrated Civil Party Storybook** | Cambodian Human Rights Action Committee (CHRAC) | The project will produce a second edition of CHRAC's book of civil party stories. The book project transforms civil parties into narrators, telling their stories both in written narratives and illustrative artworks. The book will allow those whose voices are normally perceived as powerless, and marginalized to be heard and a sense of justice delivered through recognition and acknowledgment. | Civil Peace Service (GIZ)/Federal Ministry for Economic Cooperation and Development (BMZ) | Funds secured |

| Name | Main Project Partners (implementation) | Description | Current Donors*** | Funding Status |
|---|---|---|---|---|
| **12. Publication & Distribution of Case 002/01 Judgment** | Civil Party Lead Co-Lawyers Section (LCLS) and/or ECCC | This project seeks to provide civil parties with the Case 002/01 judgment both in its full text as well as a summary version. The summary version will be the official ECCC summary and/or a specially developed summary text intended to be accessible and interesting to civil parties, their families and the general public. It will explain the judgment and civil party participation in the proceedings in layperson's terms. The text will be accompanied by informative and entertaining illustrations that will help to explain the main points of the text. | [*pending donor*] | Funds not yet secured |
| **13. Publication of Civil Party Names on ECCC Website** | ECCC | Civil party names and basic identifying information will be published in the Trial Chamber's written judgment in Case 002/01 as well being published on the ECCC website as a means to recognize the harm suffered by civil parties and acknowledge their participation in the proceedings. | Not Applicable | No funds required |

***Notes***:

** These projects are funded at a base level and additional funds are sought to expand the reach of the project to more civil parties.*

*** This project is budgeted for approximately 6 memorial sites; however, project costs can be scaled down to a lesser number of sites, if necessary.*

**** Funds totaling* **692,727.42 USD** have been raised for these projects, including **521,001.60 USD** raised by the VSS.